# ប្រាក់ថែទាំគេហដ្ឋានរបស់កម្មវិធី MEDI-CAL (Home Upkeep Allowance)សំរាប់បុគ្គលណាដែលកំពុងស្នាក់នៅជាបណ្តោះអាសន្ន ក្នុងមន្ទីរថែរក្សាមនុស្សចាស់ ឬមន្ទីរព្យាបាលដទៃទៀត

បើសិនជាលោកអ្នកកំពុងចូលរួមក្នុងកម្មវិធី Medi-Cal ហើយលោកអ្នកកំពុងរស់នៅក្នុង ឬនឹងចូលទៅសំរាកក្នុងមន្ទីរថែរក្សាមនុស្សចាស់ ឬមន្ទីរព្យាបាលដទៃទៀត លោកអ្នកប្រហែលជាអាចមានសិទ្ធិទទួលបានការកាត់ប្រាក់សំរាប់កម្មវិធី Medi-Cal ដែលគេហៅថាប្រាក់ Home Upkeep Allowance ។ ប្រាក់ Home Upkeep Allowance នឹងអាចឱ្យលោកអ្នករក្សាទុកប្រាក់ចំនួន $209 ក្នុងមួយខែ នៃប្រាក់ចំណូលរបស់លោកអ្នក សំរាប់ការមើលថែទាំ និងរក្សាផ្ទះរបស់លោកអ្នកនៅពេលលោកអ្នកកំពុងសំរាកនៅក្នុងមន្ទីរថែរក្សាមនុស្សចាស់ឬនៅក្នុងមន្ទីរព្យាបាលដទៃទៀត ជាបណ្តោះ អាសន្ន។ ប្រាក់ Home Upkeep Allowance អាចអនុញ្ញាតអោយរហូតដល់ទៅរយៈពេល 6 ខែ គិតចាប់ពីកាលបរិច្ឆេទដែលលោកអ្នកចូលទៅសំរាកក្នុងមន្ទីរថែរក្សាមនុស្សចាស់ ។

ដើម្បីមានសិទ្ធិទទួលបានប្រាក់ Home Upkeep Allowance:

- លោកអ្នកត្រូវតែមានបំណងចាកចេញពីមន្ទីរថែរក្សាមនុស្សចាស់ ហើយត្រូវវិលត្រឡប់មកផ្ទះវិញ ក្នុងរយៈពេល 6 ខែក្រោយ គិតចាប់ពីកាលបរិច្ឆេទ ដែលលោកអ្នកចាប់ផ្តើមទៅរស់នៅក្នុងមន្ទីរថែរក្សាមនុស្សចាស់ ។
- លោកអ្នកត្រូវតែមានសេចក្តីថ្លែងពេទ្យជាលាយលក្ខអក្សរ ពីផ្ទះរបស់លោកអ្នក ដោយបញ្ជាក់ថាលោកអ្នកនឹងអាចត្រឡប់មកផ្ទះវិញ ក្នុងរយៈពេល 6 ខែក្រោយ ។
- ប្តី ប្រពន្ធ ឬគ្រួសាររបស់លោកអ្នក មិនកំពុងរស់នៅក្នុងផ្ទះនោះទេ ។
- ផ្ទះរបស់លោកអ្នកកំពុងត្រូវបានគេមើលថែរក្សាឱ្យ សំរាប់ការវិលត្រឡប់មកវិញរបស់លោកអ្នក ។

បើសិនជាលោកអ្នកចង់បានព័ត៌មានបន្ថែមអំពីប្រាក់ Home Upkeep Allowance ឬចង់ដាក់ពាក្យសុំប្រាក់នេះ សូមទូរស័ព្ទទៅការិយាល័យ បំរើផ្នែកសង្គមកិច្ចប្រចាំស្រុករបស់លោកអ្នក ។